## ពិធីចុះហត្ថលេខាលើអនុស្សារណៈយោគយល់គ្នា ស្តីពីការអនុវត្តគម្រោងរបស់អង្គការ **WASHOBA** និងអង្គការ **UNICEF** រវាងក្រសួងឧស្សាហកម្ម និងសិប្បកម្ម និងអង្គការ **GRET**



នៅទីស្តីការក្រសួងឧស្សាហកម្ម និងសិប្បកម្ម នាព្រឹកថ្ងៃទី២២ ខែ ធ្នូ ឆ្នាំ២០១៤ មានរៀបចំ ពិធីចុះហត្ថលេខាលើអនុស្សារណៈយោគយល់គ្នា ស្តីពីការអនុវត្តគម្រោងរបស់អង្គការ **WASHOBA** និងអង្គការ **UNICEF** រវាងក្រសួងឧស្សាហកម្ម និងសិប្បកម្ម និងអង្គការ GRET រវាងឯកឧត្តម ចម ប្រសិទ្ធ ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម និង លោក អាំង ប៉ូរ៉ូ តំណាងប្រចាំប្រទេសនៃអង្គការ GRET ដោយមានការចូលរួមពីសំណាក់ឯកឧត្តម អស់លោក លោកស្រី ជាថ្នាក់ដឹកនាំ និង មន្ត្រីជំនាញក្រោមឱវាទក្រសួង និងតំណាងអង្គការ GRET ជាច្រើនរូបទៀត ។



លោក អាំង ប៉ូរ៉ូ តំណាងអង្គការ GRET បានមានប្រសាសន៍បញ្ជាក់ក្នុងពិធីចុះហត្ថលេខានោះ ថា: អង្គការ GRET ជាអង្គការអភិវឌ្ឍន៍ប្រទេសបារាំង ដែលបានធ្វើសកម្មភាពយ៉ាងសកម្មប្រឆាំងភាពក្រីក្រ និងវិសមភាព ចាប់តាំងពីឆ្នាំ ១៩៧៦ ។ អង្គការ GRET មានអ្នកជំនាញ ៦៨០ នាក់ ដែលកំពុងបំពេញការងារប្រកបដោយភាពច្នៃប្រឌិត និងគោលដៅយូរអង្វែងលើវិស័យចំនួន០៧ នៃការិយាល័យសាខាចំនួន ១២ ក្នុង៣០ ប្រទេស នៅលើពិភពលោក ។ អង្គការ GRET បានមកចូលរួមសកម្មភាពអភិវឌ្ឍន៍ប្រទេសកម្ពុជា ចាប់តាំងពីឆ្នាំ១៩៨៨ ។ បច្ចុប្បន្នអង្គការមានសកម្មភាពលើវិស័យផ្សេងៗដូចជា: ទឹកស្អាត និងអនាម័យ ការអភិវឌ្ឍន៍កសិកម្ម ធារាសាស្ត្រ ការពារសុខភាពសង្គម អាហាររូបត្ថម្ភ ជាដើម ។ល។ ក្នុងនោះអង្គការបាននិងកំពុងធ្វើការលើវិស័យទឹកស្អាត និងអនាម័យចាប់តាំងពីជាង១០ ឆ្នាំកន្លងមកហើយ។

លោក អាំង ប៉ូរ៉ូ បានបន្តថា :ដំណើរការគម្រោងនេះ គឺជាឱកាសមួយសម្រាប់ ក្រសួងឧស្សាហកម្ម និងសិប្បកម្ម និងអង្គការ GRET ដើម្បីអនុវត្ត នីតិវិធីនៃការជ្រើសរើសអ្នកផ្តល់សេវាទឹកស្អាត ដូចដែលបានចែងក្នុងប្រកាសលេខ ៥៦១ MIH/2014 ស្តីពីនីតិវិធីនៃការចេញ កែសម្រួល បន្ត ព្យួ និងដកហូត ប្រកាសអនុញ្ញាតឱ្យធ្វើអាជីវកម្មផ្គត់ផ្គង់ទឹកស្អាត ឱ្យកាន់តែប្រសើរឡើង ជាពិសេស បានលើកឡើងយ៉ាងច្បាស់ពីនីតិវិធីដំណើរការប្រកាសអនុញ្ញាតប្រកួតប្រជែង ដែលធានាបាននូវតម្លាភាពនៃការជ្រើសរើសអ្នកផ្តល់សេវាទឹកស្អាត។ ជាមួយគ្នានេះ វាក៏បានឆ្លុះបញ្ចាំងឱ្យឃើញការយកចិត្តទុកដាក់យ៉ាងខ្លាំងក្លារបស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម ក្នុងការធានាឱ្យបានគុណភាពសេវាល្អ និងតម្លៃលក់ទឹកសមរម្យ សម្រាប់ប្រជាពលរដ្ឋទូទាំងប្រទេស ។



មានប្រសាសន៍នាឱកាសនោះ ឯកឧត្តម ទេសរដ្ឋមន្ត្រី ចម ប្រសិទ្ធ បានថ្លែងអំណរគុណនិងវាយតម្លៃខ្ពស់ចំពោះអង្គការដៃគូទាំងឡាយ ជាពិសេសអង្គការ GRET ក្នុងកិច្ចសហការក្នុងគម្រោងអភិវឌ្ឍន៍នានា នៅកម្ពុជា ។ ក្នុងនោះមានវិស័យទឹកស្អាត ដែលជាវិស័យដ៏សំខាន់ និងជាអាទិភាពរបស់រាជរដ្ឋាភិបាល ជាពិសេសគឺការយកចិត្តទុកដាក់ដ៏ខ្ពង់ខ្ពស់ពីសំណាក់ **សម្តេចអគ្គមហាសេនាបតីតេជោ** ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ដើម្បីធ្វើយ៉ាងណាប្រជាពលរដ្ឋទទួលបានសេវាទឹកស្អាតគ្រប់ៗគ្នា ក្នុងការលើកកំពស់សុខមាលភាព និងការកាត់បន្ថយភាពរបស់ប្រជាពលរដ្ឋ ។

ជាមួយគ្នានេះ ក្រសួងឧស្សាហកម្ម និងសិប្បកម្ម ក៏កំពុងខិតខំប្រឹងប្រែងដើម្បីសម្រេចបាន គោលដៅអភិវឌ្ឍន៍សហសវត្សន៍របស់ អង្គការសហប្រជាជាតិលើវិស័យទឹកស្អាតផងដែរ ។

ឯកឧត្តម ទេសរដ្ឋមន្ត្រី ចម ប្រសិទ្ធ បានសំដែងនូវជំនឿថាៈតាមរយៈបទពិសោធន៍ និងប្រវត្តិស្នាដៃល្អរបស់អង្គការ GRET គម្រោងផ្គត់ផ្គង់ទឹកស្អាតនេះនឹងសម្រេចបានជោគជ័យ សម្រាប់ប្រជាជាពលរដ្ឋចំនួន ៥ម៉ឺននាក់ ក្នុងខេត្តគោលដៅចំនួន៣ ។ ជាមួយគ្នានេះ ឯកឧត្តមក៏បានស្នើឱ្យក្រុមហ៊ុន GRET ធ្វើការពន្យល់ដល់ប្រជាពលរដ្ឋពីតម្លៃទឹក ដែលមានភាពខុសគ្នាខ្លះពីតំបន់មួយ ទៅតំបន់ ដោយសារទាក់ទង និងប្រភពទឹក និងគុណភាពទឹកផងដែរ ។ តែទោះយ៉ាងណាគម្រោងនេះគឺបានជួយសម្រាលបន្ទុកដល់ប្រជាពលរដ្ឋជាច្រើន ជាពិសេសផ្តល់ភាពអនុគ្រោះដល់ខ្នងផ្ទះប្រជាពលរដ្ឋក្រីក្រទៅលើសេវាតបណ្តាញទឹកចូលផ្ទះជាដើម ។ ឯកឧត្តម ទេសរដ្ឋមន្ត្រីក៏បានផ្តល់ការជឿជាក់បន្ថែមថាៈការអនុវត្តគម្រោងនេះបានជោគជ័យ គឺជាបទពិសោធន៍សម្រាប់ អង្គការក្នុងការអនុវត្តគម្រោងថ្មីបន្ត នៃតំបន់គោលដៅដ៏ទៃទៀត ដែលរដ្ឋមិនទាន់មានលទ្ធភាពតបណ្តាញដល់ ។






បន្ទាប់មក ឯកឧត្តម ទេសរដ្ឋមន្ត្រី ចម ប្រសិទ្ធ និងលោក អាំង ប៉ូរ៉ូ បានអញ្ជើញចុះហត្ថលេខាលើអនុស្សារណៈ យោគយល់គ្នា ដោយមានថ្នាក់ដឹកនាំក្រសួងឧស្សាហកម្ម និងសិប្បកម្ម មន្ត្រីជំនាញ និងតំណាងអង្គការ GRET អញ្ជើញឈរជាសាក្សីផងដែរ ។

គួរបញ្ជាក់ថា:អនុស្សារណៈនេះ បានអនុវត្តលើគម្រោងផ្គត់ផ្គង់ទឹកស្អាតជូនដល់ប្រជាជន នៅឃុំចំនួន០៩ ក្នុងខេត្តចំនួន០៣ នៅក្នុងប្រទេសកម្ពុជា រួមមាន:**ទី១**–ខេត្តកំពង់ចាម : ឃុំវិហារធំ ឃុំកោះទន្ទឹម និងឃុំអូរស្វាយ ក្នុងស្រុកកំពង់សៀម **ទី២**– ខេត្តក្រចេះ: ឃុំកោះជ្រែង ឃុំដារ និងឃុំសំបុក ក្នុងស្រុកចិត្របូរី និងឃុំអូរគ្រៀងស្រុកសំបូរ **ទី៣**–ខេត្តកណ្តាលៈ ឃុំឈើខ្មៅ និងឃុំពោធិ៍បាន ក្នុងស្រុកកោះធំ ។

គោលបំណងនៃគម្រោង គឺផ្គត់ផ្គង់ទឹកស្អាតជូនដល់ប្រជាជនចំនួនប្រមាណ ៣០.០០០នាក់ នៃឃុំចំនួន០៧ ក្នុងខេត្តកំពង់ចាម និងខេត្តក្រចេះ និងប្រជាជនចំនួនប្រមាណ២០.០០០ នាក់នៃឃុំចំនួន២ ក្នុងខេត្តកណ្តាល តាមរយៈប្រព័ន្ធបណ្តាញទុយោដែលមានលក្ខណៈបច្ចេកទេសអាចទទួលយកបាន ដើម្បីលើកកំពស់សុខភាពសាធារណៈ និងជីវភាពប្រជាជនរស់នៅ ក្នុងឃុំទាំងមូល និងការគាំទ្រដល់អ្នកផ្តល់សេវាទឹកស្អាតនៅតាមទីប្រជុំជនទាំងនោះ ។

កម្មវិធីនេះអនុវត្តគម្រោងចំនួន២ រួមមាន:–អង្គការ WASHOBA ជាជំនួយរបស់ AUSAID និង Fonds Suez Environment Innitiatives នូវថវិកា ២៤១.៧៤០ ដុល្លារអាមេរិក (ពុំរាប់បញ្ចូលថវិការបស់ប្រតិបត្តិករទេ) ហើយមានរយៈពេលអនុវត្តចំនួន២ ឆ្នាំ(ខែសីហា ឆ្នាំ២០១៣ ដល់ខែសីហា ឆ្នាម២០១៥)–អង្គការ GRET នឹងអនុវត្តគម្រោងនេះគឺ:–គោរពតាមគោលការណ៍ណែនាំជាតិ–សាកល្បងនីតិវិធីថ្មី ដែលបានចែងក្នុងប្រកាសលេខ ៤៦១ MIH/2014 ចុះថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០១៤–អនុវត្តសកម្មភាពស្របតាមតម្រូវការរបស់អ្នកផ្តល់ជំនួយ–ការជ្រើសរើសអ្នកផ្តល់សេវាទឹកស្អាត ។ រីឯ គម្រោង UNICEF នៅទីប្រជុំជនឈើខ្មៅ និងពោធិ៍បាន បច្ចុប្បន្នមានប្រតិបត្តិកររួចហើយ តែអ្នកទាំងនោះពុំទាន់មាន

ប្រកាសអនុញ្ញាតពីក្រសួងឧស្សាហកម្ម និងសិប្បកម្ម នៅឡើយ ។ ចំណែក គម្រោង WASHOBA នឹងត្រូវធ្វើការដេញថ្លៃជ្រើសរើសប្រតិបត្តិករនៅទីប្រជុំជនគ្រប់គោលដៅទាំង៧ ក្នុងខេត្តកំពង់ចាម និងក្រចេះ ។